អត្ថបទ ធម៌ទេសនា

ស្ដីអំពី

# “ព្រះឱវាទ បី”

ភិក្ខុ **កែវ-អ៊ុន** ឬ **សំអៀន**

**“ អភិញ្ញានសីលោ ”**

វត្ត **សម្ដេចព្រះមហាឃោសានន្ទ**

“សាខាមជ្ឈមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរអន្ដរជាតិ”

ទីក្រុងអូកឡិនដ៍ រដ្ឋកាលីហ្វ័រនីញ៉ា

សហរដ្ឋ អាមេរិក

សុក្រ១៥កើតចេត្រ, ម្សាញ់បញ្ចស័ក ព.ស.២៥៥៦; ទី០៥ឧសភា គ.ស.២០១៣

សូមលោកអ្នក មេត្តានឹកឈ្មោះខ្ញុំ,ហើយឧទ្ទិសកុសលឲ្យដល់ខ្ញុំផង!

## អត្ថបទធម៌ទេសនាស្ដីអំពី ព្រះឱវាទបី

ព្រះឱវាទបី,ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលបញ្ជាក់ន័យរួមឲ្យខ្លីហើយខ្លឹម!ព្រះធម៌ជាព្រះបរមពុទ្ធោវាទដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងចាប់តាំងពីព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធមករហូតមកដល់ពេលដែលព្រះអង្គស្ដេចចូលកាន់ព្រះបរមបរិនិព្វានក្នុងរយៈពេល៤៥ព្រះវស្សាគឺ៤៥ឆ្នាំនោះ,មានច្រើនណាស់មានដល់ទៅ៨ម៉ឺន៤ពាន់ព្រះធម្មក្ខ័ន្ធឬ៨ម៉ឺន៤ពាន់ន័យ,ឯណោះ!បើញែកជាគម្ពីរមាន៣គម្ពីរគឺគម្ពីរព្រះវិន័យ១,គម្ពីរព្រះសូត្រ(សុត្តន្តៈ)១,គម្ពីរព្រះអភិធម្ម១។បើគិតជាសៀវភៅមាន១១០សៀវភៅហើយក្រាស់ៗទៀតផង,ព្រះធម៌៨ម៉ឺន៤ពាន់ធម្មក្ខន្ធនេះបើរួមឲ្យខ្លីហើយខ្លឹម មកនៅត្រឹមតែ៣ព្រះឱស្ឋ ឬ៣ម៉ាត់ប៉ុណ្ណោះគឺៈទី១-សព្វបាបស្ស អករណំ ការមិនធ្វើបាបគ្រប់យ៉ាង។ ទី២-កុសលស្សូបសម្បទា គួរខំធ្វើអំពើល្អ"បុណ្យ"ឲ្យបានច្រើនគ្រប់ៗគ្នា! ទី៣-សចិត្តបរិយោទបនំ គួរខំសំអាតចិត្តរបស់ខ្លួនឲ្យស្អាតល្អគ្រប់ៗគ្នា ឯតំ ពុទ្ធានសាសនំ ទាំង៣នេះឯងជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ!។ សាធុសប្បុរសទាំងឡាយ!ព្រះធម៌រាប់ម៉ឺនព្រះធម្មក្ខ័ន្ធនោះក៏រួមចូលមកក្នុងព្រះឱវាទទាំង៣ម៉ាត់នេះទាំងអស់,គឺធម៌ណាក៏ដោយក៏រួមចូលមកក្នុងព្រះឱវាទតែ៣ម៉ាត់ហ្នឹង! ប៉ុណ្ណឹង! ឲ្យតែធម៌របស់ព្រះពុទ្ធ,ហៅថា"ព្រះឱវាទបាតិមោក្ខហើយព្រះឱវាទបាតិមោក្ខនេះជាធម៌ដែលយើងជាអ្នកកាន់ព្រះពុទ្ធសាសនាគួរចេះគួរចាំគ្រប់ៗគ្នា!។ ពីព្រោះអ្នកកាន់ព្រះពុទ្ធសាសនាខ្លះមានសទ្ធាច្រើនមែនប៉ុន្តែជួនកាលមិនបានចេះមិនបានចាំព្រះពុទ្ធដីកាខ្លីៗខ្លឹមៗហ្នឹងទេ! , បើមិនចាំហើយធ្វើម៉េចនឹងដឹងថាៈតើ!ព្រះពុទ្ធប្រដៅមនុស្សថាម៉េច ?ហើយព្រះអង្គប្រដៅនោះតើល្អឬមិនល្អយ៉ាងណានោះ ?ដូច្នេះយើងអ្នកកាន់ព្រះពុទ្ធសាសនាគួរតែចេះគួរតែចាំនូវគោលធម៌ខ្លីៗខ្លឹមៗហ្នឹងដែរ,បើមិនបានចាំច្រើនចាំតែ៣ម៉ាត់ហ្នឹងប៉ុណ្ណឹងក៏បានដែរ!។ រួចបើចាំហើយ!ក៏គួរតែយល់នូវអត្ថន័យ

យល់សេចក្តីក្នុងគោលធម៌នីមួយៗនោះឲ្យបានត្រឹមត្រូវផង,ទើបគ្រប់គ្រាន់។ព្រះឱវាទប្រការទី១-ថាៈសព្វបាបស្ស អករណំ ការមិនធ្វើបាបអាក្រក់គ្រប់យ៉ាង,ចំណុចត្រង់នេះអស់លោកអ្នកគប្បីពិចារណាឲ្យបាបានយល់ច្បាស់អំពីពាក្យថា"បាប", ថាតើសភាវៈអ្វីទៅ ដែលហៅថាបាប ?ឬថាស្អីទៅបាបហ្នឹង ?ចម្លើយៈកម្មឬអំពើណាដែលប្រកបដោយលោភៈទោសៈមោហៈគឺសេចក្តីលោភលន់,សេចក្តីក្រោធខឹង,សេចក្តីល្ងង់មិនដឹងខុសត្រូវ,វង្វេងភាន់ច្រឡំ,នេះហើយដែលហៅថា"បាប"។ បើនិយាយតាមផ្លូវធម៌ថាៈ អំពើណាដែលនាំអ្នកធ្វើឲ្យទៅ កាន់អបាយ, ឲ្យទៅកាន់ទុគ្គតិ,អំពើណាដែលនាំអ្នកធ្វើឲ្យទៅកាន់នរក នោះហើយដែលហៅថា"បាប",ឬបើនិយាយជាភាសាខ្មែរយើងសុទ្ធសាធទៅថាៈ គឺអំពើអាក្រក់គ្រប់យ៉ាងដែលហៅថា"បាប"នោះ។ បាប មានលោភៈទោសៈមោហៈទាំង៣នេះជាសមុដ្ឋាន-ជាឫសគល់ ។ លោភៈទោសៈមោហៈនេះជាតួបាបផងជាមេនាំឲ្យមនុស្សធ្វើបាបគ្រប់យ៉ាងបានផង, ដូចជាមនុស្សដែលសំឡាប់ឬប្រើគេក្តី ដែលលួចឬប្រើគេក្តី ឬដែលប្រព្រឹត្តខុសក្នុងកាមក្តីដែលនិយាយពាក្យមិនពិត,អាក្រក់,កុហកបោកប្រាស់គេក្តីដែលផឹកទឹកស្រវឹងឬស្រវឹងឬញៀនក្នុងគ្រឿងស្រវឹងគ្រឿងញៀនអ្វីៗផ្សេងៗក្តី ដែលធ្វើយ៉ាងនេះបាន! ក៏ព្រោះតែលោភៈទោសៈមោហៈនេះជាបច្ច័យ គឺព្រោះតែមេបាបទាំង៣នេះវាជំរុញឲ្យធ្វើ, ទើបមនុស្សធ្វើទៅកើតសូមយល់ឲ្យច្បាស់អញ្ចឹង។អំពើ!ឬសកម្មភាពដែលមនុស្សធ្វើបាបកើតនោះ បានដល់ កាយវាចានិងចិត្តរបស់មនុស្សហ្នឹងឯង,បើតាមភាសាពុទ្ធសាសន៍ហៅថាៈកាយកម្ម,វចីកម្ម,មនោកម្ម។ រួចការដែលខំព្យាយាមកំចាត់! ឬខំព្យាយាមរារាំងមិនឲ្យបាបវាកើតឡើងបានតាមកាយ វាចាចិត្តរបស់យើងនេះហើយដែលហៅថា"មិនធ្វើបាបគ្រប់យ៉ាង"នោះ!។ បាបដែលមនុស្សធ្វើបានតាមផ្លូវកាយមាន៣យ៉ាងធ្វើបានតាមផ្លូវវាចាមាន៤យ៉ាង,ធ្វើបានតាមផ្លូវចិត្តមាន៣យ៉ាង។ បាប

ដែលមនុស្សធ្វើឲ្យកើតឡើងបានតាមផ្លូវកាយមាន៣យ៉ាងនោះគឺៈទី១
បាណាតិបាត,ទី២-អទិន្នាទាន,និងទី៣-កាមេសុ មិច្ឆាចារៈ។បាបទី១-
បាណាតិបាត នោះសំដៅយកអំពើដែលសំឡាប់សត្វមានជីវិតរស់ឲ្យ
ស្លាប់, សំឡាប់ដោយខ្លួនឯងផ្ទាល់ក្តីប្រើគេឲ្យសំឡាប់ក្តី ឬក៏គ្រាន់តែ
ឃុបឃិតសមគំនិតក្តីក៏ឈ្មោះថា បានធ្វើបាបដូចគ្នា!។ សីលបាណា
ការហាមមិនឲ្យសំឡាប់នេះព្រះពុទ្ធមិនមែនហាមមិនឲ្យសំឡាប់ត្រឹម
តែស្រមោច,សង្ការ,មាន់,ទា,ជ្រូក,គោ,ជាដើម ប៉ុណ្ណោះទេ ព្រោះការ
សំឡាប់ទាំងអស់នេះ វាមិនដែលមានប្រតិកម្មអ្វីពីសត្វទាំងអស់នោះ
ទេ! ប៉ុន្តែក៏មិនមែនមានន័យថាឲ្យសំឡាប់សត្វទាំងអស់នោះដែរ!!។
បើតាមព្រះពុទ្ធបំណងគឺព្រះអង្គហាមមនុស្សទាំងអស់គ្នានៅលើពិភព
លោកទាំងមូលនេះមិនថាជាតិណាទេ!គឺមិនឲ្យសំឡាប់មនុស្សដូចគ្នា
តែម្តង។ព្រោះមានព្រះពុទ្ធដីកាបញ្ជាក់ច្បាស់ថាៈយោ បន ភិក្ខុ សញ្ចិ-
ច្ចមនុស្សវិគ្គហំ ជីវីតា វោ រោបេតិ អសមណោ ហោតិ អសក្យបុត្តិយោ
ភិក្ខុណាមួយក្លែងសម្លាប់សត្វមានរាងកាយជាមនុស្សឲ្យផុតចាកជីវិត
ភិក្ខុនោះមិនមែនជាសមណៈមិនមែនជាសក្យបុត្តឡើយគឺថាមិនមែន
ជាកូន-ចៅរបស់តថាគតទេ!, ព្រះពុទ្ធពោលច្បាស់អញ្ចឹង! ច្បាស់ថាៈ
សត្វមានរាងកាយជាមនុស្ស, រួចបើមានរាងកាយជាមនុស្សហើយ,គឺ
មនុស្សហ្នឹងឯងតែម្តង!។ពាក្យ“ភិក្ខុ”នេះ ព្រះពុទ្ធពោលដល់គ្រហស្ថ
ផងដែរ-ព្រោះសំដៅមនុស្សណាដែលឃើញភ័យនៅក្នុងសង្សារវដ្ត។
ហេតុបានជាព្រះពុទ្ធហាមមនុស្សមិនឲ្យសម្លាប់មនុស្សដូចគ្នា! ព្រោះ
មនុស្សកាលណាសម្លាប់មនុស្សដូចគ្នាវាអាក្រក់មើលណាស់! វាជាអំ
ពើបាបធ្ងន់ខ្លាំងណាស់, វានាំឲ្យមានកម្មពៀរវេរានឹងគ្នាធំធេងណាស់!
វាខុសនឹងច្បាប់ធម្មជាតិធ្ងន់ធ្ងរណាស់ផង។ពីព្រោះថាៈ=មនុស្ស!សុទ្ធ
តែមាន“សិទ្ធិ”រស់នៅដូចគ្នាតាំងពីកំណើតមកម្ល៉េះ!=មនុស្សមានសិទ្ធិ
ស្រឡាញ់ជីវិតដូចគ្នាទាំងអស់គ្នា! សូម្បីសត្វតិរច្ឆានក៏វាចេះស្រឡាញ់

ជីវិតរបស់វាដែរ!។ដូច្នេះ!ជាមនុស្សមិនគួរសម្លាប់មនុស្សដូចគ្នាទេ!។ សាធុសប្បុរសទាំងឡាយ!សូមពិនិត្យគិតពិចារណាបន្តិចទៅមើលថាៈ លើពិភពលោកនេះទាំងមូលពេលបច្ចុប្បន្នហ្នឹង,សព្វថ្ងៃហ្នឹងនៅកន្លែងណាដែលមានការសម្លាប់គ្នាដូចនៅ(អ៊ីរ៉ាក់)ជាដើម,តើមានវិនាសកម្មយ៉ាងណា?មានសេចក្តីវិនាសអន្តរាយធំធេងប៉ុនណា?ហើយតើវានឹងមានសោកនាដកម្មដល់កំរឹតណា?? ព្រោះអ្នកដែលទទួលរងការឈឺចាប់,មិនព្រមនៅស្ងៀមទេ!។ ព្រះពុទ្ធទ្រង់ជ្រាបហេតុ-ផលនេះច្បាស់ណាស់,ទើបបានជាព្រះអង្គទូន្មានថាៈ ជាមនុស្ស!កុំសម្លាប់មនុស្សដូចគ្នានោះ។ រីឯការសម្លាប់នេះទៀតសោត សូម្បីតែសត្វតិរច្ឆានក៏មិនគួរសម្លាប់ដែរ! ព្រោះប្រសិនបើមនុស្សណាប្រព្រឹត្តធ្វើ,គឺសម្លាប់ញយដងផ្ទួនគ្នាយូរៗទៅ, បាបវារឹតតែកកផ្តុំត្រួតគ្នាច្រើនឡើងៗហើយ, ឯផលរបស់បាបនោះក៏វាកកផ្តុំច្រើនឡើងៗទៅតាមនោះដែរ,កាលណាវាកកផ្តុំច្រើនឡើងៗដូច្នេះវាក៏អាចផ្តល់ផលជាបាបដល់អ្នកធ្វើនោះក្នុងពេលបច្ចុប្បន្ននេះជាក់ស្តែងទាន់ភ្នែកក៏មាន,ដូចជារឿងចុន្ទសូករិកៈនិងរឿងគោឃាតកៈកាលពីជំនាន់ព្រះអញ្ជឹង! គឺចុន្ទសូករិកៈជាអ្នកសម្លាប់ជ្រូកយកសាច់លក់ចិញ្ចឹមជីវិត,ការសម្លាប់របស់នាយចុន្ទនេះវាប្លែកពីគេ, គឺពេលសម្លាប់ម្តងៗគាត់មិនយកកាំបិត ឬលំពែងទៅចាក់សម្លាប់ទេ! គឺគាត់យកទឹកក្តៅកំពុងពុះ ទៅចាក់បង្អកចូលក្នុងមាត់ជ្រូកតែម្តង! ចាក់ហើយចាក់ទៀតៗចាក់ទាល់តែជ្រូកនោះស្លាប់។ លុះជ្រូកស្លាប់ហើយគាត់យកដំបងឈើខ្លឹម៤ជ្រុងទៅវាយសំពងសព្វសាច់ជ្រូក,វាយហើយវាយទៀតៗ! វាយឲ្យទាល់តែណៃនសាច់, គាត់ថាវាយឲ្យណៃនសាច់ទើបមានទម្ងន់ថ្លឹងលក់បានថ្លៃ, គាត់ធ្វើរបៀបនេះក្នុង១ថ្ងៃៗមិនដឹងជាអស់ជ្រូកប៉ុន្មាន?ក្នុង១ខែៗមិនដឹងអស់ជ្រូកប៉ុន្មាន?ហើយជ្រូកនោះៗតើវាក្តៅយ៉ាងណា? វាវេទនាយ៉ាងណា?វេទនាក្តៅទាល់តែស្លាប់។ គាត់ធ្វើរបៀបនេះអស់រយៈពេល៥៥ឆ្នាំគត់,តើវាអស់ជ្រូកប៉ុន្មានទៅ?

រួចបាបវានឹងកកផ្គុំប៉ុន្មានតម្រួតទៅ?។អំពើដ៏អាក្រក់សាហាវបែបហ្នឹង ផលជាបាបរបស់អំពើហ្នឹង! វាមិនបង្អង់យូរទេ, ដែលវាកកផ្គុំយូរៗទៅ ច្រើនឡើងៗទៅ,វាក៏ផ្ទុះឡើងផ្តល់ផលបាបដល់នាយចុន្ទក្នុងពេលជា បច្ចុប្បន្ននេះភ្លាមៗទាន់ភ្នែកជាក់ស្តែង។គឺនៅពេលមួយដែលគាត់ធ្លាក់ ខ្លួនមានជម្ងឺ,ក្នុងគម្ពីរចែងថាៈផលបាបនោះវាបណ្តាលឲ្យមានជាកំដៅ ភ្លើងពីក្នុងនរកឆួលឆេះឡើងមកដុតរោលគាត់ឲ្យក្តៅក្រហល់ក្រហាយ អន្ទះអន្ទែង,បំរះននាលស្ទុះឆ្លេឆ្លាៗ វារទៅដោយក្បាលជង្គង់ទៅមកៗ ពាសពេញតែក្នុងផ្ទះ, ស្រែករោទ៍យ៉ាងខ្លាំង! សម្រែកដូចជ្រូក,អត់ដេក អត់ពួនៗ,អត់បាយអត់ទឹកៗ, តែរបៀបនេះអស់រយៈពេល៧ថ្ងៃ៧យប់ ស្រែករោទ៍ៗទាល់តែស្អួមស្អាំង!ស្លេតស្លាំង! មានតែស្បែកដណ្តប់ឆ្អឹង ស្រែករោទ៍!ទាល់តែដាច់ខ្យល់ស្លាប់នៅពេលដែលកំពុងតែបំរះននាល នោះទៅ, អំពើអាក្រក់បែបហ្នឹងបាបវាឲ្យផលអាក្រក់អញ្ចឹង។នាយចុន្ទ ស្លាប់ហើយមិនមែនចប់ត្រឹមស្លាប់ប៉ុណ្ណឹងទេ,គឺធ្លាក់ទៅកើតក្នុងនរករង ទុក្ខលំបាកវេទនាយ៉ាងក្រៃលែង! អស់កាលដ៏យូរអង្វែងណាស់!តទៅ ទៀត។រឿងមួយទៀតក៏អាក្រក់ខ្លាំងដូចគ្នានេះដែរ, គឺរឿងគោឃាតកៈ អ្នកសំឡាប់គោបរិភោគ, គាត់តែងបរិភោគសាច់គោរាល់ថ្ងៃបើថ្ងៃណា មិនមានសាច់គោទេគាត់មិនបរិភោគបាយទេ,ហើយនិងលក់សាច់គោ ខ្លះចិញ្ចឹមជីវិតផង!។ នៅថ្ងៃមួយនោះមានមិត្រសំឡាញ់ម្នាក់ទៅលេង ផ្ទះរបស់គាត់, ពេលត្រឡប់ទៅវិញសំឡាញ់នោះ ក៏បានយកសាច់គោ ដែលគាត់ទុកសំរាប់បរិភោគនោះបាត់ទៅ,ដល់ពេលភរិយារបស់គាត់ លើកបាយមកបរិភោគមិនមានសាច់គោ, គោឃាតកៈក៏កាន់កាំបិត១ ចុះពីលើផ្ទះដើររ៉ុយឆ្ពោះទៅរោងគោគាត់ចាប់គោ១មកហើយក៏លូកដៃ ទៅចាប់ទាញអណ្តាតគោពីក្នុងមាត់គោមកហើយយកកាំបិតកាត់ប៉ាត់ ដាច់មក, រួចយកទៅអាំងចំអិនដើម្បីបរិភោគជាមួយបាយ។លោកអ្នក សប្បុរសគិតមើលថាៈគោរស់! ហើយកាត់អណ្តាតដាច់មក, តើវាឈឺ

យ៉ាងណា ?រួចវាប្រកាច់ប្រកិនយ៉ាងណា ? ក្នុងគម្ពីរចែងថាៈក្នុងពេលមួយរំពេចនោះក្រោយពេលដែលគាត់អាំងអណ្តាតគោឆ្អិនហើយយកមកដើម្បីបរិភោគជាមួយបាយ,គ្រាន់តែគាត់ហាមាត់ឡើងនឹងបរិភោគស្រាប់តែផលបាបកម្មវាបណ្តាលឲ្យអណ្តាតរបស់គាត់ដាច់ធ្លាក់ចុះមកក្នុងចានបាយឃើញបាបទាន់ហន់ជាក់ស្តែងទាន់ភ្នែកភ្លាមៗ, ហើយក៏ស្រែករោទ៍ៗសម្រែកដូចគោ!ប្រកាច់ប្រកិនៗត្រឡប់ត្រឡិនៗមិនយូរប៉ុន្មានក៏ដាច់ខ្យល់ស្លាប់ភ្លាមក្នុងពេលនោះទៅរួចធ្លាក់ទៅកើតក្នុងនរកឯណោះភ្លាមដែរ! រងទុក្ខលំបាកវេទនាយ៉ាងក្រៃលែង!មិនដឹងជាអស់រយៈកាលប៉ុន្មានតទៅទៀតទេ។( ច្បាប់ខ្លះថាគាត់ខាំអណ្តាត )នែ!ការសំឡាប់នេះ  សូម្បីសត្វតិរច្ឆានដែលមិនមានគុណធម៌នៅក្នុងខ្លួនផង! បាបវាឲ្យផលជាទុក្ខលំបាកដ៏ខ្លាំងក្លាម្លឹងៗ,ចុះទំរាំបើមនុស្សដែលមានគុណធម៌នៅក្នុងខ្លួន!តើអ្នកដែលសំឡាប់គេនោះនឹងត្រូវទទួលនូវផលបាបជាទុក្ខទារុណខ្លាំងក្លាដល់កំរិតណាទៅហ្ន៎!?  ព្រោះ ហេតុដូច្នោះហើយបានជាព្រះពុទ្ធទូន្មានថាៈជាមនុស្សនៅលើពិភពលោកនេះទាំងមូលទាំងអស់គ្នាចូរកុំសំឡាប់គ្នា! សូម្បីសត្វតិរច្ឆានក៏ដោយ!។ តទៅនេះបាបដែលមនុស្សធ្វើឲ្យកើតឡើងតាមផ្លូវកាយដែរ!ប្រការទី២គឺអទិន្នាទានៗ,នេះបានខាងអំពើដែលលួចលាក់ឆក់ដណ្តើមកេងប្រវ័ញ្ចទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលគេមិនបានឲ្យដោយកាយឬដោយវាចា!។ ការលួចឬប្រើគេឲ្យលួចនេះជាអំពើបាប! បាបវាឲ្យផលជាទុក្ខលំបាកខ្លាំងណាស់,ដូចពាក្យចាស់បុរាណលោកពោលថា“លួចគេវាគ្រាន់ទេប្រយត្ន័ម្ចាស់គេទាន់វាក្រែល”។ អំពើបាបរឿងលួចគេហ្នឹង!វាច្រើនតែឲ្យផលនៅក្នុងពេលបច្ចុប្បន្ននេះផង។ដូចមានរឿងមួយកាលពីជំនាន់ព្រះថាៈមាន“តាបស”កុហកម្នាក់អាស្រ័យនៅសាលាមួយជិតក្រុងពា-រាណសី,មានកុដុម្ពីក៏ម្នាក់(អ្នកមាននៅជនបទ) បាននិមន្តតាបសនោះឲ្យទៅឆាន់នៅផ្ទះរបស់គាត់រាល់ថ្ងៃ,ដល់ពេលមួយស្រុកទេសកើតមានក្តី

អន្តរាយដោយចោរភ័យ គឺមានចោរ!ចេះតែលបចូលលួចទ្រព្យសម្បត្តិអ្នកស្រុកជាញឹកញយៗ,កុដុម្ពីក៍ក៏កើតក្តីបារម្ភពីទ្រព្យសម្បត្តិរបស់គាត់ក៏បានយកមាស១ក្រឡ! ទៅកប់ទុកក្រោមសាលានោះ ហើយបានផ្ញើនឹងតាបសនោះផង,ដល់កន្លងពេលយូរៗទៅតាបសកំហូចនោះក៏មានចិត្តបាបកើតឡើង,ហើយបានលួចយកមាសនោះទៅលាក់ទុកនៅឯទីកន្លែងផ្សេង,នៅពេលដែលទៅឆាន់នៅផ្ទះកុដុម្ពីក៍បាននិយាយជាមួយកុដុម្ពីក៍ថា“នែញោម!អាត្មាមកនៅកន្លែងនេះដូចជាយូរដែរហើយ! រួចវាច្របូកច្របល់លាយឡំទៅដោយពួកមនុស្សម្នាជាច្រើនពេកទៅអាត្មាមានការធុញទ្រាន់ណាស់,ដូចជារកធម៌អាថ៌អ្វីមិនឃើញទេ,ដូច្នេះអាត្មាសូមលាញោមទៅរកកន្លែងផ្សេងទៀតហើយមើលទៅដើម្បីឲ្យមានការស្ងប់ស្ងាត់បន្តិចនឹងបានចំរើនធម៌ស្ងប់ស្រួល”។ តាបស,ទោះបីកុដុម្ពីក៍ឃាត់យ៉ាងណាក៏មិនព្រមនៅដែរ, រួចតាបសកំហូចនោះបានប្រើល្បិចដ៏ពិសេសមួយទៀតគឺនៅពេលដែលចុះពីផ្ទះកុដុម្ពីក៍ គាត់ដើរសសៀរទៅរកដំបូលផ្ទះដែលទាប ហើយគាត់ធ្វើជារុញផ្នួងសក់របស់គាត់ឲ្យទៅប៉ះនឹងសំយ៉ាបដំបូលផ្ទះធ្វើឲ្យស្បូវ២, ៣សរសៃជាប់នឹងផ្នួងសក់របស់គាត់ហើយចុះចេញទៅ(តាបសដែលបួសក្រៅព្រះពុទ្ធសាសនាគេបួងសក់កំប៉ូកៗ)លុះទៅបានបន្តិចក៏ត្រឡប់មកវិញ, កុដុម្ពីក៍សួរថា“ ឱ! លោកម្ចាស់មានការអ្វីទើបត្រឡប់មកវិញ ?”តាបសកំហូចមិនទាន់ឆ្លើយទេគាត់យកដៃទៅហូតស្បូវ២-៣សរសៃ អំពីផ្នួងសក់មកហើយហុចឲ្យទៅកុដុម្ពីក៍,ទើបនិយាយថាៈនែញោម! អាត្មាចុះពីផ្ទះញោមអម្បាញ់មិញទៅមិនបានជាចាប់អារម្មណ៍! វាស្រាប់តែជាប់ស្បូវ២-៣សរសៃនឹងផ្នួងសក់របស់អាត្មាទៅ! រួចអាត្មាខ្លាចវាចូលក្នុងបទ អទិន្នាទាន,បានជាអាត្មាយកមកជូនញោមវិញ,ព្រោះអាត្មាជាអ្នកបួស។នេះជាសំដីបង្វែងដានដើម្បីកុំឲ្យគេសង្ស័យទៅថ្ងៃក្រោយ។ប៉ុន្តែមានអីនៅពេលនោះមានអ្នកដែលគេមានបញ្ញាជាវិស័យពោធិសត្វគេបានឮសំដីនោះ

ហើយគេក៏យល់ច្បាស់ថាៈជាសំដីបង្វែងដានរឿងអ្វីមួយហើយទើបគេ គេសួរទៅកុដុម្ពីក៍ ថាៈនែ! អ្នក! តើអ្នកធ្លាប់បានយករបស់អ្វីទៅផ្ញើនឹង តាបសនោះដែរឬទេ ? កុដុម្ពីក៍ថាៈ មានលោកម្ចាស់!មានផ្ញើមាស១ដុំ ដែរ,ពោធិសត្វប្រាប់ថាបើដូច្នេះពិតជាតាបសនោះគាត់លួចយកហើយ បានជាគាត់ធ្វើនិងនិយាយបែបហ្នឹងនោះ!។ លុះបានឮដូច្នោះហើយក៏ នាំគ្នាទៅមើលឯសាលាឃើញថា មាសនោះបាត់មែនក៏គិតគ្នាថា "យី! បើអញ្ចឹងត្រូវនាំគ្នាតាមឬ!អឺតាមក៏តាម"ក៏នាំគ្នាតាមទៅលុះតាមទៅៗ ក៏បានទៅជួបនឹងតាបសនោះមែន!។ លុះទាន់ហើយនាំគ្នាត្រួតពិនិត្យ ខ្លួនប្រាណរបស់តាបសក៏បានឃើញមាសនោះនៅខ្លួនតាបស, ក៏បាន នាំគ្នាវាយទះតប់ តាបស នោះឲ្យពកមុខពកមាត់ទ្រមខ្លួនយ៉ាងខ្លាំង។ នែ! នេះហើយដែលបុរាណលោកពោលថាៈលួចគេវាគ្រាន់,ដល់ម្ចាស់ គេទាន់វាក្រៃល, គឺបើម្ចាស់គេទាន់ហើយគេមិនទុកឲ្យយូរពេលទេគេ ផ្តល់ដំបូន្មានភ្លាមៗមួយរំពេច! យ៉ាងស្រាលបំផុតត្រឹមមួយសន្លប់តូច ដូចជាតាបសនេះអញ្ចឹង! ។ ការលួចវាច្រើនតែទទួលផលបាបភ្លាមៗ ក្នុងពេលបច្ចុប្បន្ននេះដូច្នេះឯង!។ តទៅ អំពើបាប ដែលមនុស្សធ្វើឲ្យ កើតឡើងតាមផ្លូវកាយដែរប្រការទី៣-គឺ កាមេសុ មិច្ឆាចារៈៗ នេះ សំ ដៅយកការប្រព្រឹត្តិខុសក្នុងផ្លូវកាម!។ ការប្រព្រឹត្តិខុសក្នុងផ្លូវកាមេនេះ បើជាបុរស បានខាងអំពើដែលលបលាក់លួចប្រព្រឹត្តមោះមិនគាប់ជា មួយស្ត្រីដទៃក្រៅពីភរិយារបស់ខ្លួន,បើជាស្ត្រីវិញបានខាងអំពើប្រព្រឹត្ត កន្លងចិត្តស្វាមីរបស់ខ្លួនទៅប្រព្រឹត្តមោះមិនគាប់ជាមួយនិងបុរសដទៃ ក្រៅពីស្វាមីរបស់ខ្លួន!ការប្រព្រឹត្តិមិនគាប់ដូច្នេះ គឺសុទ្ធតែជាអំពើបាប, ហើយអំពើបាបនេះ វាឲ្យផលមកជាទុក្ខៗលំបាកណាស់។ រួចប្រសិន បើមានល្បិចចេះលួចលបលាក់គេចវេះយ៉ាងណា មិនឲ្យគេឃើញមិន ឲ្យគេដឹងក្នុងជាតិជាបច្ចុប្បន្ននេះក៏ដោយ! ក៏គង់ទៅទទួលរងទុក្ខក្នុង អបាយទាំងឡាយ, មាននរក ជាដើមនៅឯជាតិខាងមុខនោះមិនខាន

ឡើយ។ ដូចមានរឿងនាងមល្លិកាជាព្រះទេពីរបស់ព្រះបាទបសេនទិ-កោសលមហាក្សត្រក្រុងសាវត្ថី,ព្រះនាងគ្រាន់តែប្រព្រឹត្តមោះមិនគាប់ជាមួយសត្វសុនខគឺឆ្កែឈ្មោលដែលចិញ្ចឹមដ៏ស្និតស្នាលផងក៏គង់ធ្លាក់ទៅនរកដែរ!។ គឺកាលដែលព្រះរាជាទ្រង់ជ្រាបពីរឿងនេះព្រះអង្គទ្រង់ត្រាស់សួរ,នាងមល្លិកានាងមានបញ្ញាឆ្លាតណាស់!នាងមានល្បិចខ្ពស់ណាស់នាងឆ្លើយបំប្លែងសេចក្ដីធ្វើឲ្យទាល់តែព្រះរាជាជឿជាក់ថានាងឥតបានប្រព្រឹត្តមោះមិនគាប់អ្វីទេ។ប៉ុន្តែដល់ពេលដែលនាងជិតស្លាប់,នាងមានវិប្បដិសារីស្ដាយក្រោយថាឱ!-អាត្មាអញ!មិនគួរប្រព្រឹត្តមោះមិនគាប់ហើយកុហកព្រះស្វាមីអញ្ចឹងសោះ!។ ដោយការប្រព្រឹត្តិមោះមិនគាប់នោះជា បាប វាជិតជាប់នឹងជវ័នចិត្តគឺដង្ហើមចុងក្រោយរបស់នាង,ពេលដែលនាងកំពុងតែដកដង្ហើមធ្ងឹតផ្ដក់,រួចនឹកឃើញអំពើនោះលុះដាច់ខ្យល់ស្លាប់ទៅបដិសន្ធិវិញ្ញាណក៏ឆក់នាងរឹងទម្លាក់ទៅឲ្យកើតក្នុងនរកឯណោះភ្លាមមួយរំពេចអស់រយៈពេល៧ថ្ងៃរបស់មនុស្ស,ប៉ុន្តែ៧ថ្ងៃរបស់មនុស្សប្រហែលជា១ប៉ប្រិចភ្នែកប៉ុណ្ណោះ!ពីព្រោះទេវតាគេមានអាយុវែងណាស់។ នាងមល្លិកាជាស្ត្រីមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាមុតមាំខ្លាំងណាស់,នាងបានធ្វើបុណ្យច្រើនណាស់ពីមុនៗមកទាស់តែប្រព្រឹត្តខុសបន្តិចប៉ុណ្ណឹងសោះ។ ដោយអំណាចផលានិសង្សរបស់បុណ្យដែលនាងបានធ្វើច្រើនៗពីមុនមកនោះក៏បានបណ្ដាលឲ្យនាងបានរំដោះរួចពីនរកបានទៅកើតនៅតុសិតសួគ៌ទេវលោកទៅ! ។ សាធុរៅហែសាធុសប្បុរសទាំងឡាយ! ផលបាបដែលកើតឡើងពីការប្រព្រឹត្តខុសក្នុងផ្លូវកាមគុណនេះ មិនចាំបាច់និយាយដល់ទៅអនាគតជាតិខាងមុខនោះទេ! សូម្បីក្នុងពេលបច្ចុប្បន្ននេះ ក៏បាបនឹងវាឲ្យផលដ៏កាចសាហាវគួរឲ្យភ័យខ្លាច,គួរឲ្យតក់ស្លុតខ្លាំងណាស់ដែរ។ ដូចជាលោកអ្នកសប្បុរសទាំងឡាយ!ធ្លាប់បានដឹងបានឮបានឃើញស្ទើរតែគ្រប់ៗគ្នាមកហើយថានៅលើពិភពលោកនេះសព្វថ្ងៃហ្នឹងពួកមនុស្ស

ដែលមិនស្តាប់ព្រះពុទ្ធមិនជឿព្រះពុទ្ធមិនគោរពតាមធម៌របស់ព្រះពុទ្ធ ដែលព្រះអង្គទូន្មានថាចូរកុំប្រព្រឹត្តឲ្យខុសក្នុងផ្លូវកាមនោះ! រួចពួកគេ បានប្រព្រឹត្តខុសក្នុងផ្លូវកាមនេះខ្លួនគេ! ដែលបណ្តាលឲ្យកើតទៅជា រោគអ្វីម៉្យាងនោះហើយអេដស៍ រួចបានទៅរកលោកវេជ្ជបណ្ឌិតៗបាន សារភាពហើយថា,រកវិធីអ្វីផ្សំថ្នាំព្យាបាលមិនបានទេ!រួចនាំគ្នាភ័យស ស្លន់ សស្លោពេញទាំងពិភពលោកដោះស្រាយមិនរួច, ឯរោគនេះបើ មនុស្សណាកើតហើយ,ដេកចាំតែថ្ងៃស្លាប់តែប៉ុណ្ណោះ!។ មានអ្នកខ្លះ បានទៅសុំអង្វរសាវ័ករបស់ព្រះពុទ្ធគឺលោកសង្ឃខ្លះឲ្យជួយឃោសនា ឲ្យពួកខ្លួនពីរឿងហ្នឹងផង,ធ្វើឲ្យលោកសង្ឃច្របូកច្របល់ជាមួយ,តើវា បានប្រយោជន៍អ្វីទៅ?បើខ្លួនឯងមិនស្តាប់ព្រះពុទ្ធ ហើយប្រព្រឹត្តខុស ខ្លួនឯងនោះ?។ បើតាមពណ៌មានតៗមកថាៈអ្នកស្លាប់ពីរឿងហ្នឹងមិន តិចទេ!នៅលើដុំពិភពលោកនេះសព្វថ្ងៃនេះនោះ! បើដូច្នេះលោកអ្នក ស្តាប់ទាំងឡាយ,គួរគិតពិចារណាឡើងវិញហើយនាំគ្នាគោរពតាមព្រះ ពុទ្ធទាំងអស់គ្នាទៅដែលព្រះអង្គទ្រង់ទូន្មានថាៈជាមនុស្សនៅលើពិភព លោកនេះទាំងមូលទាំងអស់គ្នា,ទាំងប្រុសទាំងស្រីចូរកុំប្រព្រឹត្តឲ្យខុស ក្នុងផ្លូវកាម!។ <u>តទៅនិយាយអំពីបាប</u>ដែលមនុស្សធ្វើឲ្យកើតឡើងបាន តាមផ្លូវ វាចាដែលហៅថា វចីកម្ម ជាវចីទុច្ចរិត វិញម្តង ឬបើនិយាយឲ្យ ស្រួលស្តាប់បំផុតនោះគឺបាបដែលកើតអំពីមាត់។ សាធុសប្បុរសទាំង ឡាយ! បាបដែលកើតអំពីមាត់នេះវាមានឥទ្ធិពលខ្លាំងក្លាណាស់, គួរ ប្រុងប្រយត្ន័ឲ្យមែនទែនណាស់!! ដូចជាបុរាណជាបុព្វបុរសរបស់ខ្មែរ យើងលោកបានពោលជា ទិសស្លោក ទុកមកឲ្យយើងពិចារណាទាំង អស់គ្នាថា "អណ្តាតជាអាទិ៍កន្លងបានសុខទុក្ខផងពីព្រោះអណ្តាត"។ លោកពោលច្បាស់អញ្ចឹង,ហើយលោកបានបញ្ជាក់ន័យបន្ថែមទៀតថា "ពាក្យសំដីនេះបើប្រើជាអាវុធវាជាអាវុធដ៏មុតស្រួចណាស់!ប៉ុន្តែពាក្យ សំដីដដែលហ្នឹង, ប្រសិនបើប្រើជាឱសថវិញវាក៏ជាឱសថដ៏ពូកែយ៉ាង

សក្តិសិទ្ធខ្លាំងណាស់ដែរ!”។ បុរាណភាសិតទាំងអស់នេះខ្ញុំសុំមិនធ្វើអត្ថាធិប្បាយទេសូមលោកសប្បុរសទាំងឡាយ!មេត្តាធ្វើការពិចារណាដោយខ្លួនឯងផងចុះ។ បាបដែលកើតអំពីមាត់នេះ ព្រះពុទ្ធសម្តែងថាៈ មាន៤យ៉ាងគឺៈទី១-មុសាវាទ,ទី២-បិសុណាវាទ,ទី៣-ផរុសវាទ, និងទី៤-សម្ផប្បលាបវាទ, ខ្ញុំនឹងធ្វើអត្ថាធិប្បាយនូវមាតិកានិមួយៗ! ឲ្យបានពិស្តារបន្តិចៗជូនដូចតទៅៈគឺទី១-មុសាវាទៗ នេះបានខាងសំដីដែលនិយាយមិនពិត,កុហកបោកប្រាស់,គឺៈរឿងអ្វីមិនពិតទេនិយាយថាពិត, រឿងអ្វីមិនមែនទេនិយាយថាមែនដូច្នេះជាដើម! ការនិយាយពាក្យមិនពិតនេះ វាជាបាប! រួចបាបហ្នឹងវាធ្ងន់ស្រាលទៅតាមសាច់រឿងនោះៗទៀត,ដូចជារឿងនាងចិញ្ចាមានវិកា,ហៅថា“ចិញ្ចា”ដែលពួកអន្យតិរ្ថិយ៍គេជួលនាងឲ្យទៅនិយាយពាក្យមួលបង្កាច់ព្រះពុទ្ធអញ្ចឹង!, រឿងនោះបាបធ្ងន់ណាស់!។គឺពួកតិរ្ថិយ៍គេបង្គាប់នាងឲ្យយកដុំឈើទៅចងភ្ជាប់នៅត្រង់ពោះរបស់នាងហើយឲ្យនាងស្លៀកសំពត់ពទ្ធ័ពីក្រៅធ្វើឲ្យដូចជាស្ត្រីមានផ្ទៃពោះជិតគ្រប់ខែអញ្ចឹង!។ រួចឲ្យនាងទៅឈរចំពីមុខគ្រែដែលព្រះពុទ្ធកំពុងប្រទានព្រះធម៌ទេសនាប្រោស!ពុទ្ធបរិស័ទនៅឯវត្តជេតពន, ប្រាប់នាងឲ្យចង្អុលទៅរកព្រះពុទ្ធហើយឲ្យនាងពោលពាក្យធ្វើយ៉ាងណាក្នុងន័យឲ្យអ្នកស្តាប់គេស្តាប់ហើយយល់បានថានាងធ្លាប់បានទៅរួមរក្សជាមួយព្រះពុទ្ធហើយទើបធ្វើឲ្យនាងមានផ្ទៃពោះនោះ! ព្រះពុទ្ធទោះបីនាងចិញ្ចាបានពោលពាក្យមួលបង្កាច់ច្រើនយ៉ាងណាក៏ដោយក៏ព្រះអង្គពុំមានព្រះទ័យចាប់អារម្មណ៍អ្វីបន្តិចសោះឡើយ!។ចំណែកពួកពុទ្ធបរិស័ទគេស្រឡាំងកាំងគ្រប់គ្នាហាក់ដូចជាស្លៅភ្នែកគ្រប់ៗគ្នា! ព្រោះវាជារឿងដែលគេនឹកស្មានមិនដល់រួចស្រាប់តែវាកើតមានឡើងដូច្នេះគួរឲ្យហួសចិត្ត។ ដោយពាក្យពោលមួលបង្កាច់ព្រះអរហន្តសម្មាសម្ពុទ្ធបែបនេះ វាមានបាបធ្ងន់ពេក!, ក៏ក្តៅរំជួលទៅដល់អាស្នារបស់ព្រះឥន្ទដែលមាន រហស្សនាម ថា“សហស្សនេត្រ” ក្នុងន័យថាៈ

ក្រឡេកតែ១ភ្លែតដឹងរឿងរាប់ពាន់ប្រការ,ព្រះឥន្ទក៏បើកនេត្រាទិព្វមក បានឃើញសកម្មភាព និងសំដីរបស់នាងចិញ្ហាដ៏គួរឲ្យស្អប់ខ្ពើមនេះក៏ ប្រើវិស្សកម្មទេវបុត្ត ឲ្យចុះមកនិមិត្តខ្លួនធ្វើជាសត្វកណ្ដុរ ចូលទៅកាត់ ខ្សែចងដុំឈើត្រង់ពោះនាង ចិញ្ហា បណ្ដាលឲ្យដុំឈើដាច់ធ្លាក់ចុះមក ធ្វើឲ្យនាងបានឃើញផលបាបរបស់ខ្លួនយ៉ាងទាន់ហន់បំផុតជាក់ស្ដែង ទាន់ភ្នែកភ្លាមៗ,ធ្វើឲ្យនាងដល់នូវក្ដីអាម៉ាស់បំផុត!, អាប់មុខអាប់មាត់ ក្នុងកណ្ដាលចំណោមមហាជនពុទ្ធបរិស័ទៗគេចោមរោមត្មះតិះដៀល នាងជាអនេកប្រការ!ធ្វើឲ្យនាងងើបមុខមិនរួច!ៗ នែ! មុសាវាទ មាត់ ដែលនិយាយពាក្យសំដីមិនពិត, ហើយមិនត្រឹមតែមិនពិតទេថែមទាំង មួលបង្កាច់ទៅទៀត,រួចមិនមួលបង្កាច់មនុស្សធម្មតាទៅជាមួលបង្កាច់ ព្រះពុទ្ធទៅទៀតនោះបាបវារឹតតែធ្ងន់ធ្ងរណាស់!, ធ្ងន់រហូតដល់ធ្វើឲ្យ ឃើញ ផលបាប ជាក់ស្ដែងទាន់ភ្នែកយ៉ាងហ្នឹង! មិនត្រឹមតែប៉ុណ្ណឹងទេ នាងចិញ្ហា លុះចេញផុតពីព្រះភក្ត្រព្រះពុទ្ធទៅ! ត្រូវធរណីស្រូបទម្លាក់ ឲ្យទៅកើតក្នុងអវីចិនរកភ្លាមក្នុងពេលនោះដែរ! ។ បាបដែលកើតអំពី មាត់ដោយប្រើពាក្យមុសាវាទចប់ត្រឹមប៉ុណ្ណេះ។<u>បាបទី២-បិសុណាវាទ</u> ៗ នេះបានខាងមាត់ដែលនិយាយពាក្យសំដីចាក់ចុច, ញុះញង់,បំបែក បំបាក់,យករឿងពីម្ខាងទៅប្រាប់ម្ខាងទៀត,ធ្វើឲ្យគេស្អប់ខ្ពើមគ្នា,ឲ្យគេ ឈ្លោះគ្នាឬឲ្យគេបែកបាក់សាមគ្គីគ្នា, រួចបើនិយាយបំបែកបំបាក់ដល់ លោកអ្នកមានគុណធម៌ខ្ពង់ខ្ពស់ផងនោះនោះបាបកាន់តែធ្ងន់ណាស់! ទៅទៀតធ្ងន់រហូតឲ្យទៅកើតជាប្រេតឯណោះ,ដូចជារឿងសូករៈប្រេត អញ្ចឹង, រឿងនេះមានដំណាលថាៈនៅក្នុងសាសនានៃព្រះពុទ្ធព្រះនាម កស្សបៈមានភិក្ខុ១រូប,បាននិយាយញុះញង់ព្រះថេរៈ២អង្គ!ដែលមាន សីលាទិគុណដ៏ខ្ពង់ខ្ពស់, ឲ្យលោកបែកបាក់សាមគ្គីគ្នាដោយផលបាប កម្មនៃការនិយាយញុះញង់នោះធ្វើឲ្យភិក្ខុអ្នកនិយាយញុះញង់នោះលុះ ស្លាប់ទៅធ្លាក់ទៅកើតក្នុងអវីចិនរកអស់រយៈពេល១ពុទ្ធន្តរ គឺ១ចន្លោះ

ព្រះពុទ្ធ, លុះរួចរដោះពីនោះមកដល់មកក្នុងសាសនាព្រះពុទ្ធសមណៈ គោតមយើងនេះបានមកកើតជាប្រេត,បានរួចពីនរកហើយមកកើតជា ប្រេតទៀតមានឈ្មោះថាសូករៈប្រេត, ព្រោះមានខ្លួនជាមនុស្សក្បាល ជាជ្រូក,នៅលើភ្នំគិជ្ឈកូដថាមានដង្កូវធំៗចាក់រុកពាសពេញមាត់និងវារ វិរមរវាមពាសពេញខ្លួន,រងទុក្ខវេទនាយ៉ាងក្រៃលែង។នៃមាត់ដែលប្រើ សំដី បិសុណាវាទ បំបែកបំបាក់លោកអ្នកមានគុណធម៌ខ្ពង់ខ្ពស់វាមាន បាបធ្ងន់យ៉ាងហ្នឹង!។ បិសុណាវាទចប់ប៉ុណ្ណេះ។ បាបទី៣-ផរុសវាទៗ នេះបានខាងមាត់ដែលនិយាយពាក្យសំដីអាក្រក់!អសុរោះខ្មោះខ្មួរមិន គួរស្តាប់ឬជេរប្រទេចអ្វីផ្សេងៗក៏រាប់បញ្ចូលក្នុង ផរុសវាទ ទាំងអស់!។ មាត់ដែលប្រើពាក្យផរុសវាទគ្រោតគ្រាតជេរប្រទេចនេះអស់លោកអ្នក អ្នកប្រហែលជាធ្លាប់បានជួបប្រទះខ្លះ មិនខាន! គឺថាប្រសិនបើមនុស្ស ណាម្នាក់ប្រើពាក្យនេះជេរប្រទេចទៅលើនរណាម្នាក់ផ្សេងទៀតបើអ្នក ផ្សេងនោះមិនមានធម៌ខន្តីទេគឺអត់ទ្រាំមិនបានទេ, មុខជាខឹងច្រឡោត ជេរតបមកវិញមិនខានបើដូច្នោះមិនគ្រាន់តែប្រើត្រឹមតែពាក្យសំដីនោះ ប៉ុណ្ណោះទេ! គឺពិតជាអាចមានប្រើដល់ទៅដំបងព្រនង់ឬកាំបិតពូថៅអ្វី ទៀតផងក៏មិនដឹង ?ឬក៏ដល់ទៅអាវុធបាញ់ប្រហារគ្នាផងក៏អាចមាន។ បើជាស្ត្រីៗវិញយ៉ាងហោចណាស់ក៏ត្រឹមប្រវាយប្រតប់គ្នា ហែកសំពត់ ហែកខោ-អាវមិនខាន!។ មាត់ដែលប្រើពាក្យសំដីផរុសវាទនេះ បើជេរ ប្រទេចលោកអ្នកមានគុណធម៌ដ៏ខ្ពង់ខ្ពស់ផងនោះ!,នោះមានបាបកាន់ តែធ្ងន់ខ្លាំងណាស់ទៅទៀត,ដូចជារឿងភិក្ខុកោកាលិកៈជាមិត្តជិតស្និទ្ធ របស់ភិក្ខុទេវទត្តអញ្ចឹង!, កោកាលិកៈនេះបានជេរប្រទេចព្រះសារីបុត្ត និងព្រះមោគ្គល្លានជាព្រះអរហន្តសាវ័កស្តាំ-ឆ្វេងរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងគម្ពីរចែងថាៈកោកាលិកៈភិក្ខុកំពុងតែជេរ, ដោយអំពើបាបនេះ មានទម្ងន់ធ្ងន់ពេកផែនដីទ្រមិនរួចក៏ប្រេះបែកចំហរស្រូបទម្លាក់ទៅក្នុង នរក ភ្លាមៗ ក្នុងពេលដែលកំពុងជេរនោះយ៉ាងទាន់ហន់បំផុត! ។ នៃ!

កាលពីជំនាន់ព្រះ បាប វាឲ្យផលជាក់ស្ដែងយ៉ាងហ្នឹង។ ដូច្នេះមុនស្ស យើងទាំងអស់គ្នានៅលើពិភពលោកនេះទាំងមូល! គប្បីប្រុងប្រយត្ន័ មាត់កុំប្រើផរុសវាទនេះធ្វើអ្វីពីព្រោះផរុសវាទកាលណាដល់កំរិតរបស់វាវានឹងទាញយើងទម្លាក់ទៅនរកហើយ!។ ជាបន្តទៅនេះ និយាយអំពី បាប ទី៤- គឺសម្ផប្បលាបវាទ។ នេះបានខាងមាត់ដែលនិយាយពាក្យសំដីឡេះឡោះ,មិនសង្រួម,ឥតប្រយោជន៍,មនុស្សណាដែលប្រើពាក្យសំដី សម្ផប្បលាបៈ ប៉ផ្លេះប៉ផ្លោះនេះ ជាការសម្ដែងឲ្យអ្នកផងគេមើលឃើញចរិយាមារយាទរបស់មនុស្សនោះ ឡឡៃ,ឡឡ,ពាលា, អាវាសែអញ្ចឹងផងដែរ។ មាត់ដែលប្រើសំដី សម្ផប្បលាបៈនេះ វាតែងបណ្ដាលឲ្យមានទោសច្រើនប្រការ ជួនកាលអាចឲ្យមានអន្តរាយដល់ជីវិតផងក៏មាន,ដូចមានរឿងសំដែងក្នុងស្រីហិតោបទេសថាៈមានសត្វអណ្ដើក១ជាសំឡាញ់ជាមួយសត្វហង្ស១គូ, អណ្ដើកនោះវាចង់ទៅរស់នៅឯបឹង១ជិតភ្នំចិត្តកូដ, បានសុំឲ្យហង្ស១គូនោះ ខាំពាំកំណាត់ឈើ១ចុងម្ខាងម្នាក់, រួចខ្លួនឯងជាអណ្ដើកខំខាំតោងត្រង់កណ្ដាលនាំយកទៅ។ មុននឹងចេញទៅ ហង្សបានដាស់តឿនអណ្ដើកថាៈនែ!សំឡាញ់! នៅពេលដែលយើងកំពុងនាំសំឡាញ់ទៅ!, ប្រសិនបើមានមនុស្សម្នាគេនិយាយចំអកឡកលេងឲ្យបែបណាក៏ដោយ,សុំសំឡាញ់រក្សាធម៌ខន្តីអត់ទ្រាំឲ្យបាន,កុំឆ្លើយតបទៅគេវិញ, បើសំឡាញ់ឆ្លើយតបទៅគេវិញវានឹងមានគ្រោះថ្នាក់ធំហើយ! រួចហង្សក៏បានហើរនាំអណ្ដើក! កាត់ពីលើភូមិអ្នកស្រុកទៅ,លុះពួកក្មេងៗឃ្វាលគោវាឃើញដូច្នោះក្មេងខ្លះក៏ស្រែកឡើងថា,នែ!វ៉ឺយគ្នាយើង!មើលអណ្ដើកចេះហោះមើលអណ្ដើកហោះវ៉ឺយ!យីះ! បើបានវាមកអញយកវាទៅស្លកាវីហើយវ៉ី!, ឯក្មេងខ្លះទៀតថា បើបានវាមកអញយកវាទៅដុតស៊ីឥឡូវឲ្យឆ្ងាញ់មាត់ភ្លាម!ៗ, ក្មេងខ្លះទៀតថា,បើបានវាមកអញយកទៅស្ងោស៊ីឯផ្ទះឲ្យបានគ្នាច្រើនអណ្ដើកឮដូច្នោះបែបឡើងជោរ!ចង់មានអំនួត! រួចភ្លេចពាក្យសន្យាក៏

ឆ្លើយឡើងថា:នែ!ពួកក្មេងៗរាល់គ្នា! ឯងនាំគ្នាស៊ីតែផេះទៅ!អណ្តើក ឆ្លើយបានតែប៉ុណ្ណេះកំពុងតែធ្លាក់មកនោះ! ក៏ប៉ះទង្គិចស្នូកនឹងផែនដី គ្រាំង!បែកស្នូកខ្ទេចស្លាប់ទៅ!។ នែ! មាត់ដែលប្រើសំដីសម្ផប្បលាបៈ មិនសង្រួមប្រយត្ន័បណ្តាលឲ្យមានគ្រោះថ្នាក់ស្លាប់ ដូចជាអណ្តើកនេះ ក៏មាន។ ដូច្នេះបានជាព្រះពុទ្ធទូន្មានថា:ជាមនុស្សនៅក្នុងពិភពលោក នេះទាំងមូលទាំងអស់គ្នាកុំប្រើពាក្យសំដីទាំង៤ម៉ាត់នេះធ្វើអី! ព្រោះវា សុទ្ធតែជាបាប, ហើយបាបនេះវាឲ្យផលមកសុទ្ធតែជាទុក្ខលំបាកខ្លាំង ណាស់, រួចការរងទុក្ខនៅនាឋានរបស់មនុស្សយើងនេះ គួរឲ្យតក់ស្លុត ណាស់ទៅហើយ,ចុះទំរាំបើសេចក្តីទុក្ខនៅក្នុងឋាន នរក.ប្រេតនោះតើ វាជាទុក្ខលំបាកវេទនាខ្លោចផ្សាដល់កំរិតណាទៅ? ដូច្នេះបើចៀសវាង បានចៀសទៅកុំប្រើអី,កុំនិយាយអី! វចីទុច្ចរិតទាំង៤យ៉ាងនេះនោះ!។ បាបដែលកើតអំពីវចីកម្មហៅថាវចីទុច្ចរិតចប់ប៉ុណ្ណេះឯង!។ តទៅនេះ និយាយអំពីបាបដែលកើតឡើងតាមផ្លូវចិត្ត ហៅថា មនោកម្ម វិញ,ម្តង មនោកម្មនេះមាន៣យ៉ាង:អភិជ្ឈា១,ព្យាបាទ:១,មិច្ឆាទិដ្ឋិ១,១-អភិជ្ឈា បានដល់មនុស្សដែលមានគំនិតលោភលន់ចង់បានខុសទំនង,សំឡឹងរំ ពៃទ្រព្យសម្បត្តិរបស់អ្នកដទៃចង់ឲ្យបានមកជារបស់ខ្លួនទោះបីធ្វើតាម ល្បិចណា?មធ្យោបាយណាមួយក៏ដោយឲ្យតែបានមក បាបហើយ!។ អភិជ្ឈានិយាយខ្លីប៉ុណ្ណឹងចុះព្រោះអភិជ្ឈាមានន័យប្រហាក់ប្រហែលគ្នា និងអទិន្នាទានដែរ,រួចអទិន្នាទានបានសំដែងរួចមកហើយ!។តទៅនេះ សំដែងអំពីមនោកម្មទី២គឺព្យាបាទ:ៗបាបដែលកើតអំពីព្យាបាទនេះគឺ មនុស្សណាដែលមានចិត្តអាក្រក់គំនុំគុំគួនចងអាឃាតចង់បំផ្លាញដល់ ប្រយោជន៍និងសេចក្តីសុខរបស់អ្នកដទៃឲ្យគេវិនាសអន្តរាយហ្នឹងបាប ហើយបាបដែលកើតពីព្យាបាទនេះវាអាក្រក់ជាងអភិជ្ឈាឆ្ងាយណាស់ !គឺបាបដែលកើតអំពីព្យាបាទនេះ វាអាចបណ្តាលឲ្យកើតទៅជាមាន កម្មពៀរវេរានិងគ្នា!រាប់ជាតិរាប់កប្ប៍ទៅមុខទៀតក៏មាន!។ ដូចជារឿង

ស្ត្រី២នាក់ប្រពន្ធដើមនិងប្រពន្ធចុងចងពៀរនិងគ្នាអញ្ចឹង! ដំណើររឿងនោះដូចតទៅនេះ! ប្រពន្ធដើមជាស្ត្រីអារមិនមានកូន, រួចខ្លាចប្តីទៅរកប្រពន្ធថ្មីទៀត ក៏បានទៅស្តីដណ្តឹងស្រីម្នាក់មកឲ្យប្តី, ដោយគិតថា:ឲ្យស្រីនោះនៅក្រោមអំណាចរបស់ខ្លួន!, ក៏ប៉ុន្តែដល់ស្រីនោះគេមានគភ៌ឡើង,នាងប្រពន្ធដើមក៏កើតមានចិត្តច្រណែន,ប្រចណ្ឌ,ព្យាបាទដោយគិតថា: បើស្រីនោះមានកូនមក, ប្តីប្រាកដជាស្រឡាញ់នាងប្រពន្ធចុងនោះជាងខ្លួនហើយ,រួចទៅអនាគត,គេរមត៌កអ្វីនឹងបានទៅនាងនិងកូននាងជាមិនខាន,នែ!នាងប្រពន្ធដើមគិតដល់ទៅម្លឹងហ្ន៎!ដូច្នោះនាងជាប្រពន្ធដើមក៏ចាប់ផ្សំថ្នាំពន្លូតឲ្យនាងប្រពន្ធចុងផឹក,ប្រពន្ធចុងផឹករហូតដល់រលូតគភ៌អស់២ដង, លុះដល់ដងទី៣ ដោយថ្នាំនោះវាមានកម្លាំងខ្លាំងពេកក៏បណ្តាលឲ្យនាងប្រពន្ធចុងស្លាប់ទាំងកូននៅក្នុងផ្ទៃនោះទៅប៉ុន្តែមុននឹងដាច់ខ្យល់ស្លាប់នាងប្រពន្ធចុងបានដឹងច្បាស់ថា:ឱ!ប្រពន្ធដើមធ្វើបាបអញហើយតើ!ទើបនាងប្រពន្ធចុងបានតាំងចិត្តចងពៀរថាថា"ឱ!ព្រះជាម្ចាស់!បើទៅជាតិខាងមុខទៀតទោះបីនាងខ្ញុំបានកើតជាអ្វីក៏ដោយក៏សូមឲ្យនាងខ្ញុំបានស៊ីកូនរបស់នាងនោះកុំខានឲ្យសោះ!" នាងតាំងចិត្តដូច្នេះហើយក៏ស្លាប់ទៅលុះប្រពន្ធចុងស្លាប់ទៅ,ទើបប្តីដឹងរឿងនោះច្បាស់,ប្តីក៏បានវាយនាងជាប្រពន្ធដើមយ៉ាងដំណំ,ដំណំរហូតដល់មិនយូរប៉ុន្មាននាងប្រពន្ធដើមក៏ស្លាប់ទៅដែរប៉ុន្តែមុននឹងស្លាប់នាងក៏បានតាំងចិត្តចងពៀរដូចជានាងប្រពន្ធចុងដែរ។ដោយនាងបានតាំងចិត្តចងពៀរនឹងគ្នាទាំង២នាក់ដូច្នេះពៀរនោះក៏វាបានជាប់តគ្នាមែន!។ រឿងដោយសង្ខេបថាជាតិទី១-ប្រពន្ធចុងកើតជាមេឆ្មា,ប្រពនដើមកើតជាមេមាន់, ឆ្មាស៊ីកូនមាន់អស់!ៗ។ ទី២-ប្រពន្ធចុងកើតជាមេសត្វម្រឹគព្រន្ធដើមកើតជាមេខ្លា,ខ្លាស៊ីកូនម្រឹគអស់ៗទៅ។ ទី៣-ប្រពន្ធចុងកើតជាយក្ខិណី,ប្រពន្ធដើមកើតជានាងកុលធីតាៗកូនអ្នកស្រុកធម្មតា។ស៊ីតែកូនគ្នារាល់ៗជាតិដូច្នេះ, នៅជាតិទី៣នេះ ប្រពន្ធចុងដែលបានកើត

ជាយក្ខិណីបានស៊ីកូនប្រពន្ធដើមដែលកើតជានាងកុលធីតាអស់២ដង ដែរ, វេលាដែលប្រារព្ធនឹងស៊ីនៅលើកទី៣នេះ, នាងកុលធីតាបានដឹង ខ្លួនមុនក៏បីកូនខ្ទីរត់ទៅឯវត្តជេតពន,ក៏យកកូនខ្ទីរបស់នាងទៅដាក់នៅ ជិតជើងគ្រែព្រះធម្មាសនៈ! ដែលព្រះពុទ្ធកំពុងប្រទានព្រះធម៌ទេសនា ប្រោសពុទ្ធបរិស័ទ ដើម្បីសូមព្រះអង្គទ្រង់ព្រះមេត្តា! ជួយសង្គ្រោះជីវិត កូនរបស់នាងផង,ពេលនោះនាងយក្ខិណីក៏តាមទៅដល់ដែរ, តែសាច់ រឿងនេះព្រះពុទ្ធទ្រង់ស្តេចជ្រាបសព្វគ្រប់អស់ហើយព្រះអង្គក៏មានព្រះ ពុទ្ធដីកាថាៈ"ម្នាលនាងទាំង២នាក់!ចូរនាងឈប់ចងពៀរនឹងគ្នាតទៅ! ដ្បិតពៀរនេះ!ប្រសិនបើនាងមិនបានមកជួបនឹងតថាគតទេ!, ពៀរនេះ នឹងនៅតែចងជាប់នឹងគ្នារាប់ជាតិទៅមុខទៀតឥតឈប់ទេ!, ប៉ុន្តែឥឡូវ នាងទាំង២បានមកជួបនឹងតថាគតហើយ,នាងហៅចំជាមានសំណាង ធំហើយ!ដូច្នេះចូរនាងឈប់ចងពៀរនឹងគ្នាទៅ!, បើនាងតាំងចិត្តឈប់ ចងពៀរនឹងគ្នា!ពៀរនេះនឹងរលត់អស់ត្រឹមនេះហើយ!។ ឯនាងទាំង២ នាក់ក៏ស្ថិតនៅស្ងៀម!ចាំស្តាប់ព្រះពុទ្ធ,ព្រះពុទ្ធស្តេចទ្រង់ប្រទានព្រះដំ បូន្មានដល់នាងៗជាអនេកបរិយាយ,នាងៗលុះបានស្តាប់ព្រះឱវាទជា ដំបូន្មានដ៏ល្អប្រសើរដែលដូចជាឱសថទិព្វដោយផ្ទាល់ពីព្រះឱស្ឋរបស់ ព្រះពុទ្ធ,នាងទាំង២នាក់ក៏មានស្មារតីភ្ញាក់រលឹកដ៏ល្អប្រសើរឡើងវិញ! រួចបានប្តេជ្ញាចិត្តថាឈប់ចងពៀរនឹងគ្នាតាំងពីពេលនោះទៅហើយបែរ ត្រឡប់ជាមានចិត្តមេត្តាស្នេហាស្រឡាញ់រាប់រកគ្នាយ៉ាងល្អីកល្អឺនដ៏ល្អ ប្រសើរឡើងវិញនៅពេលនោះឯង!។ នែ!បាបដែលកើតឡើងអំពីការ ព្យាបាទគ្នាវាមានឥទ្ធិពលខ្លាំងក្លាយ៉ាងហ្នឹង! ប៉ុន្តែដោយសារ, រសព្រះ ធម៌ដែលផ្សាយចេញពីទឹកព្រះទ័យប្រកបដោយព្រះមហាករុណារបស់ ព្រះពុទ្ធដែលនាងៗបានស្តាប់ផ្ទាល់ពីព្រះឱស្ឋរបស់ព្រះអង្គវាពូកែសក្តិ សិទ្ធយ៉ាងហ្នឹង!ធ្វើឲ្យនាងៗបានរួចចាកផុតអំពីកម្មពៀរវេរានឹងគ្នានៅ ពេលនោះជារៀងរហូតទៅ!មិនត្រឹមតែប៉ុណ្ណឹងទេនាងបានទៅរស់នៅ

ក្នុងភូមិជាមួយគ្នាផងទៀត! ហើយឯនាងយក្ខិណីដោយវិស័យខ្លួនជាទេវតានោះនាងអាចដឹងបានថាឆ្នាំនេះមានភ្លៀងច្រើនឬតិច, ហើយក៏បានប្រាប់នាងជាសំឡាញ់ឲ្យធ្វើស្រែនៅដីទួល ឬទំនាបទៅតាមស្ថានភាពនៃទឹកភ្លៀងនោះៗគ្រប់រដូវកាល, នាងជាសំឡាញ់ក៏មានជីវភាពដ៏ល្អប្រសើរជាងមុន,ពីព្រោះនៅឆ្នាំណាដែលមានការរាំងស្ងួតអ្នកភូមិស្រុកស្កកស្រូវអស់!នាងជាសំឡាញ់ក៏នៅតែបានស្រូវល្អមានផលល្អច្រើន! ព្រោះនាងធ្វើស្រែនៅទីទំនាបតាមការណែនាំរបស់យក្ខិណីជាសំឡាញ់។ ឯអ្នកស្រុកគេឆ្ងល់នាងធ្វើស្រែមិនដែលស្កកសោះទៅសួរនាងនាងក៏បានពណ៌នាតាមទំនងនេះដល់អ្នកស្រុក,អ្នកស្រុកក៏បានទំនាក់ទំនងសហការណ៍គ្នាជាមួយនាងយក្ខិណីដ៏ល្អនាងយក្ខិណីក៏បានជាទីស្រឡាញ់ពេញចិត្តនៃអ្នកស្រុកផងទៀតដែរ។កម្មទី២ព្យាបាទចប់

<u>មនោកម្មទី៣-មិច្ឆាទិដ្ឋិ:</u> បាបដែលកើតឡើងតាមផ្លូវចិត្តហៅថាមនោកម្មជាមនោទុច្ចរិតទាំង៣យ៉ាងនេះ បណ្ឌិតលោកពោលថា: មិច្ឆាទិដ្ឋិ នេះមានបាបធ្ងន់ណាស់!ធ្ងន់ជាងអភិជ្ឈានិងព្យាបាទៈទៅទៀត, ហេតុអ្វីក៏មិច្ឆាទិដ្ឋិនេះមានបាបធ្ងន់ម្លេះ!? = បានជាមានបាបធ្ងន់ព្រោះ មិច្ឆាទិដ្ឋិ នេះប្រែថាការយល់ខុស, ពីព្រោះថាមនុស្សតែកាលណាមានការយល់ខុសហើយពិបាកនឹងកែណាស់!។មនុស្សណាដែលមានការយល់ខុសហើយគិតអ្វីក៏ខុស, និយាយាអ្វីក៏ខុស, ធ្វើអ្វីៗក៏ខុស, រួចបើធ្វើអ្វីៗខុសហើយបានផលមកវិញក៏ខុសដែរ,រួចផលដែលខុសនោះសុទ្ធតែជាទុក្ខ, ទុក្ខលំបាកណាស់!ព្រោះហេតុនោះបានជាព្រះពុទ្ធទូន្មានថាជាមនុស្សនៅលើពិភពលោកនេះទាំងមូលទាំងអស់គ្នា!,គួរកុំយល់ខុស,កុំដើរផ្លូវខុសកុំយល់អ្វីឲ្យខុសពីការពិតឲ្យសោះ!។ ចប់ព្រះឱវាទ ប្រការទី១ ៕

តទៅ ព្រះឱវាទប្រការទី២ ចែងថា: កុសលស្សូបសម្បទា ការបំពេញកុសលទាំងពួងឲ្យបរិបូរណ៍ឬគួរខំធ្វើអំពើល្អគ្រប់យ៉ាង“បុណ្យ”ឲ្យបានច្រើនគ្រប់ៗគ្នា!=សាធុសប្បុរសទាំងឡាយ!គួរយល់នូវពាក្យ“កុសល”

ថាៈតើសភាវៈអ្វីទៅដែលហៅថា“កុសល”?ចម្លើយៈទង្វើឬសកម្មភាព ដែលកំចាត់បង់នូវអំពើអាក្រក់គ្រប់យ៉ាងហៅថាកុសលហើយ,ឬថាការ ធ្វើនូវអំពើល្អគ្រប់យ៉ាងក៏ហៅថាកុសលហើយ!រួចការដែលខំព្យាយាម សន្សំធ្វើកុសលឲ្យកើតមានឡើងនៅក្នុងកាយវាចាចិត្តរបស់ខ្លួនម្នាក់ៗ នោះហើយ!ដែលហៅថាបំពេញកុសលឲ្យបរិបូរណ៌នោះ!។ កុសល! បើនិយាយអំពីសមុដ្ឋាន,ឬសគល់របស់កុសល,ព្រះពុទ្ធចង្អុលឲ្យលើក យកនូវគោលធំៗទាំង៣យ៉ាងមកបញ្ជាក់ឡើងវិញ, ឲ្យឃើញផ្ទុយអំពី បាបគឺអលោភៈសេចក្តីមិនលោភលន់,អទោសៈសេចក្តីមិនខឹងប្រទុស្ត អ្វីផ្សេងៗ,អមោហៈសេចក្តីមិនល្ងង់ដែលមិនដឹងការខុសត្រូវ!អលោភៈ អទោសៈអមោហៈទាំង៣នេះជាតួកុសលផងជាប្រភពនាំឲ្យមនុស្សធ្វើ កុសលទាំងពួងកើតបានផង,សកម្មភាព ឬប្រភពដែលនាំឲ្យធ្វើកុសល កើតឡើងបាននោះគឺកាយ,វាចា,ចិត្តរបស់យើងហ្នឹងឯង!កាយគឺយើង យករូបកាយខ្លួនប្រាណរបស់យើងទៅធ្វើ, វាចាគឺយើងយកមាត់. សំដី របស់យើងទៅនិយាយទៅប្រើ,ចិត្តគឺយើងយកចិត្តទៅគិតពិចារណាឬ ស្មឹងស្មាធ! អប់រំបន្ទំចិត្តឲ្យវាស្ងប់រម្ងាប់ជាដើម,ទាំងអស់នេះ គឺសុទ្ធតែ ជាវិធីធ្វើនាំឲ្យកើតបុណ្យកើតកុសលហើយ!។ មួយទៀត,សកម្មភាព ឬមូលដ្ឋានដែលនាំឲ្យកើតបុណ្យកុសលដែរនោះ!មាន១០យ៉ាងហៅ ថាបុញ្ញកិរិយាវត្ថុ គឺៈទី១ទានៈ បានដល់ការឲ្យនូវវត្ថុអ្វីផ្សេងៗដល់អ្នក ដទៃដែលគួរឲ្យមានមាតាបិតាជាដើម!ម្យ៉ាងឲ្យដោយសេចក្តីអនុគ្រោះ ដល់មនុស្សអ្នកក្រកំសត់ទុគ៌ត,ជរា,ពិការជាដើមដោយចិត្តមេត្តាពិតៗ ទី២-សីលៈ ការវៀរចាកមិនធ្វើអំពើបាបអាក្រក់គ្រប់យ៉ាងមានមិនសំ ឡាប់គេមិនប្រើគេឲ្យសម្លាប់!,មិនលួចគេមិនប្រើគេឲ្យលួច,មិនបាន ប្រព្រឹត្តខុសក្នុងផ្លូវកាម,មិននិយាយពាក្យអាក្រក់,កុហក បោកប្រាស់ មិនសេពផឹកទឹកស្រវឹង,គ្រឿងញៀនអ្វីផ្សេងៗជាដើម។ ទី៣-ភាវនា បានដល់ការចំរើនចិត្តសង្រួម,អប់រំចិត្តឲ្យស្ងប់រម្ងាប់មូលក្នុងអារម្មណ៍

តែមួយដោយសមថវិធីឬវិបស្សនាវិធី ជាវិធីចំរើនចិត្តឲ្យល្អក្នុងកុសលធម៌ហៅថាភាវនា។ ទី៤-អបចាយនៈ បានដល់ការបន្ទន់នូវអស្មិមានៈដែលក្រអឺត,ក្រអោងកោងព្រហើន,បន្ទន់វាឲ្យសុភាពរាបសា!, គឺចេះគោរពកោតក្រែងចាស់ព្រឹទ្ធាចារ្យឬអ្នកដែលចំរើនដោយគុណធម៌ល្អមានព្រះសង្ឃបព្វជិតឬមាតាបិតារបស់ខ្លួនផ្ទាល់ជាដើម ជាពិសេសគឺគោរពសិទ្ធិមនុស្សទូទៅឲ្យបានល្អប្រសើរផងហៅអបចាយនៈ។ ទី៥-វេយ្យាវច្ចៈ បានដល់ការជួយខ្វល់ខ្វាយក្នុងកិច្ចការបុណ្យរបស់អ្នកដទៃតាមសមគួរដោយចិត្តជ្រះថ្លាដែលផុះចេញពីដួងចិត្តបរិសុទ្ធរបស់ខ្លួន។ ទី៦-បត្តិទានៈបានដល់ការឲ្យនូវចំណែកបុណ្យដែលខ្លួនធ្វើហើយដល់អ្នកដទៃដោយចិត្តមេត្តាដោយចង់ឲ្យគេបានបុណ្យដូចខ្លួនដែរ!។ ទី៧-បត្តានុមោទនា បានដល់ការអនុមោទនាត្រេកអរតាមបុណ្យដ៏ល្អ របស់អ្នកដទៃដែលគេបានឲ្យដល់ខ្លួន; ទី៨-ធម្មទេសនាបានដល់ការពន្យល់ណែនាំអ្នកទៃឲ្យយល់ពីធម៌ ឬពីច្បាប់ពីផ្លូវត្រូវ។ ទី៩-ធម្មស្សវនៈ បានដល់ការតាំងចិត្តឲ្យល្អស្តាប់ព្រះធម៌ ដ៏ល្អដោយ យោនិសោមនសិការៈដើម្បីសេចក្តីសុខនឹងផុតទុក្ខ។ ទី១០-ទិដ្ឋុជុកម្មៈ ការធ្វើទិដ្ឋិគឺការយល់របស់ខ្លួនឲ្យត្រង់ត្រូវតាមផ្លូវ សម្មាទិដ្ឋិ តាមផ្លូវសច្ចៈយុត្តិធម៌។ នេះជាម៉ាគា,ជាផ្លូវ,ជាមូលដ្ឋានដែលធ្វើទៅនាំឲ្យកើតបុណ្យ,កើតកុសលទាំងអស់។ដូច្នេះបានជាព្រះពុទ្ធទ្រង់ទូន្មានថាៈគួរខំបំពេញកុសលទាំងពួងឲ្យបរិបូរណ៌នោះ ជាពិសេសគួរខំប្រឹងធ្វើតាម បុញ្ញកិរិយាវត្ថុ ទាំង១០ប្រការនេះឲ្យបានល្អប្រសើរថែមទៀតទៅ។ ចប់ព្រះឱវាទប្រការទី២!

<u>តទៅព្រះឱវាទប្រការទី៣-</u>ថែងថាៈសចិត្តបរិយោទបនំ ការសំអាតចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់។ ត្រង់នេះមានជាសំនួរថាៈចុះការសំអាតចិត្តរបស់ខ្លួនឲ្យស្អាតនោះ!តើសំអាតយ៉ាងម៉េចទៅ ?បើចិត្តមិនមានរូបផងចិត្តមើលមិនឃើញផង ?ចម្លើយៈឱ!សំនួរហ្នឹង!ពិបាកឆ្លើយមែន!ប៉ុន្តែសូមលោកអ្នកសប្បុរសមេត្តាធ្វើការសង្កេតពិនិត្យពិចារណាដោយយក

ចិត្តទុកដាក់ឲ្យមែនទែនតាមទំនងអត្ថន័យដែលជំរាបជូនដូចតទៅថាៈ ចិត្តជាធម្មជាតិមិនមានរូបសណ្ឋានអ្វីអាចឲ្យយើងមើលឃើញពិតមែន, ជាបរមត្ថធម៌,ល្អិតសុខុមណាស់!ជានាមធម៌,មានតែឈ្មោះសំរាប់ហៅតែប៉ុណ្ណោះ,ប៉ុន្តែវាមានលក្ខណៈពិសេសរបស់វាអាចឲ្យយើងកំណត់សំគាល់បានដែរទៅតាមចលនា រូបកាយរបស់មនុស្សយើង។ ពីព្រោះមនុស្សទាំងអស់នៅលើពិភពលោកទោះបីជាតិសាសន៍ណាក៏ដោយ, សុទ្ធតែមានចិត្តគ្រប់ៗគ្នាទាំងអស់!គ្មាននរណាអត់ចិត្តទេ,បើអត់ចិត្តគឺវិញ្ញាណនេះមនុស្សមិនអាចរស់ទេ!។ យើងមើលចិត្តមិនឃើញមែន, ប៉ុន្តែយើងដឹងច្បាស់ណាស់ថាមនុស្សសុទ្ធតែមានចិត្ត(តើមាននរណាយល់ថាមនុស្សអត់ចិត្តដែរឬទេ?)។ចិត្តជាធម្មជាតិចេះគិត,ចេះរាវរកអារម្មណ៍ផ្សេងៗ,ចិត្តអាចត្រាច់ទៅតែម្នាក់ឯងក្នុងទីដ៏ឆ្ងាយៗណាស់! ត្រឡប់មកវិញក៏លឿនរហ័សណាស់មិនមានអ្វីលឿនរហ័សស្មើនឹងចិត្តនេះឡើយ នៅលើដុំពិភពលោកទាំងមូលហ្នឹង!គ្មានអ្វីលឿនរហ័សស្មើនឹងចិត្តនេះទេ,ចិត្តចេះទទួលអារម្មណ៍ជាសុខ,ជាទុក្ខ,ចេះសប្បាយរីករាយ,ចេះទោមនស្ស-តូចចិត្ត,ចេះស្រណោះអាឡោះអាល័យ!,និងចេះសុប-សៅ!ផងដែរ!។ ចិត្ត មិនមានរូបទេ!,ប៉ុន្តែវាជា"អគ្គមេបញ្ជាការ" លើរូបកាយរបស់មនុស្សទាំងស្រុង!។រូបកាយមនុស្សទាំងអស់គ្នាហ្នឹងដែលមានចលនាអាចធ្វើសកម្មភាពអ្វីៗគ្រប់យ៉ាងបាន, គឺសុទ្ធតែមានបញ្ជាពីចិត្តទាំងអស់!ដូចមានព្រះពុទ្ធដីកាចែងថាៈ"មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា... ប្រែៈទង្វើអ្វីៗគ្រប់យ៉ាងទាំងល្អទាំងអាក្រក់, ដែលមនុស្សធ្វើកើតបាន,សុទ្ធតែសម្រេចអំពីចិត្តទាំងអស់គឺសុទ្ធតែចិត្តវាបញ្ជាទាំងអស់!។ ចិត្ត!ដែលអត់មានរូបនេះ!ពិបាកគ្រប់គ្រង ពិបាកថែរក្សា,ពិបាកទូន្មាន!,របិលរប៉ូច!ប៉ផ្លេចប៉ផ្លូចណាស់!,ព្រះពុទ្ធដីកាថា ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ  ចិត្តជាធម្មជាតិកំរើកញាប់ញ័រឃ្លេង-ឃ្លោងប៉ផ្លេកប៉ផ្លូច,រក្សាបានដោយកម្រ,ពិបាកឃាត់ឃាំងណាស់,មាន

តែអ្នកប្រាជ្ញទេ!ទើបអាចបង្វិក,ទូន្មាន,ឃាត់ឃាំងចិត្តឬទប់ចិត្តឲ្យស្ថិតនៅនឹងមួយកន្លែងបាន!។សាធុសប្បុរសទាំងឡាយ!ដើម្បីសំអាតចិត្តឲ្យស្អាតផូរផង់,បណ្ឌិតលោកឲ្យយកខន្តីធម៌និងមេត្តាធម៌ធ្វើជាទឹកដ៏ថ្លាស្អាត, រួចយកចិត្តទៅត្រាំក្នុងទឹកហ្នឹង,ផ្សំនិងសតិសម្បជញ្ញៈទុកដូចជាសាប៊ូ,ហើយដុសសំអាតដោយដៃគឺវិរិយៈ!ដុសហើយដុសទៀតៗដុសឲ្យទាល់តែស្អាត,រួចជូតសម្ងួតដោយសំឡីដ៏ទន់ស្អាត!គឺ"សន្តិ"សេចក្តីស្ងប់នោះឯង!។បើធ្វើដូច្នេះបាន!ចិត្តស្អាតផូរផង់ហើយ។ព្រះពុទ្ធទ្រង់ទូន្មានថាៈម្នាលភិក្ខុទាំងឡាយ!ចូរអ្នកយកសមថៈនិងវិបស្សនា មកធ្វើជាឃ្នាបហើយគាបឬចងក្រៀកចិត្តរបស់អ្នករួចចូរអ្នកខំព្យាយាមចំរើននូវអសុភនិមិត្តដោយយោនិសោមនសិការៈថាមិនស្អាតៗឲ្យបានរឿយៗ,យូរទៅអ្នកនឹងថ្នឹកហើយធ្វើដូច្នោះអ្នកអាចបន្សាត់បង់នូវនីវរណធម៌បន្តិចម្តង!ៗជាបណ្តើរៗទៅហើយ!។ទីខ្លះព្រះពុទ្ធទូន្មានថាៈម្នាលភិក្ខុទាំងឡាយ!អ្នកគប្បីប្រើសតិសម្បជញ្ញៈដាស់តឿនចិត្តរបស់អ្នកឲ្យឋិតនៅក្នុងទី៤ស្ថានៈគឺ ស្ថានទី១- ត្រូវតាំងចិត្តពិចារណាថាៈនែ!ចិត្តរបស់អាត្មាអញ!កុំត្រេកត្រអាលក្នុងធម៌អ្វី ដែលនាំឲ្យកើតក្តីត្រេកត្រអាល!គឺបើឃើញរូបគ្រាន់តែឃើញទៅកុំត្រេកត្រអាលអី,កុំស្រឡាញ់អីកុំជាប់ចិត្តអី ទិដ្ឋេ ទិដ្ឋមត្តំ ឃើញក៏គ្រាន់តែឃើញ,មិនប្រកាន់យកទេ,មិនជាប់ចិត្តទេ,មិនទេ!។ស្ថានទី២-ត្រូវតាំងចិត្តពិចារណាថានែ!ចិត្តរបស់អាត្មាអញកុំប្រទុស្តក្នុងធម៌ដែលជាហេតុនាំឲ្យកើតសេចក្តីប្រទុស្ត, បើឃើញរូបគ្រាន់តែឃើញទៅកុំខឹងអី,កុំប្រទុស្តអី,បើបាត់រូបទៅវិញក៏កុំខឹងអី,កុំស្រណោះអាឡោះអាល័យអី,កុំអី!។ស្ថានទី៣-ត្រូវតាំងចិត្តថាៈនែ!ចិត្តរបស់អាត្មាអញ,កុំវង្វេងក្នុងធម៌ដែលជាហេតុនាំឲ្យកើតសេចក្តីវង្វេង,គឺកុំប្រកាន់អស្មិមានៈឲ្យសោះ! ដែលជាហេតុនាំឲ្យប្រាសចាកពីសេចក្តីពិត,នាំឲ្យប្រាសចាកពីធម៌ពិត។ ស្ថានទី៤ត្រូវតាំងចិត្តថាៈនែចិត្តរបស់អាត្មាអញ,កុំស្រវឹងក្នុងធម៌ដែលជាហេតុនាំឲ្យកើតសេចក្តីស្រវឹង!មាន

ការស្រវឹងដោយលាភៈសក្ការៈឬស្រវឹង"អំណាច" ជាដើម,ការស្រវឹងអំណាចមានគ្រោះថ្នាក់ធំធេងណាស់!ម្នាលភិក្ខុទាំងឡាយ! កាលណាអ្នកបានបង្វឹកចិត្តរបស់អ្នកតាមស្ថានបែបនេះរឿយៗទៅចិត្តរបស់អ្នកនឹងបានស្ងប់បានស្អាតជាខណៈៗតទៅហើយ!មួយបែបទៀតព្រះពុទ្ធឲ្យពិចារណាក្នុងសាមញ្ញលក្ខណធម៌,គឺធម៌ជាទីអស់ទៅសូន្យទៅតាមការចាស់,ការឈឺ,ការស្លាប់ដោយឲ្យយកធម៌"អភិណ្ហបច្ចវេក្ខណៈ"មកពិចារណាដូច្នេះថា ជរាធម្មោម្ហិ ជរំ អនតីតោ ឱ!មនុស្សសត្វនៅលើដុំពិភពលោកទាំងមូលទាំងអស់គ្នា! សុទ្ធតែមានការចាស់ជរាជាធម្មតាមិនមាននរណាម្នាក់អាចកន្លងការចាស់ជរា! នេះទៅបានឡើយ! ទាំងខ្លួនរបស់អាត្មាអញនេះឯងក៏ដូចគ្នា!។ ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ ឱ! មនុស្សសត្វនៅលើដុំពិភពលោកនេះទាំងមូលទាំងអស់គ្នាសុទ្ធតែមានជម្ងឺដម្កាត់ជាធម្មតាមិនមាននរណាម្នាក់អាចកន្លងការឈឺថ្កាត់នេះទៅបានឡើយទាំងខ្លួនរបស់អាត្មាអញនេះឯងក៏ដូចគ្នា, មរណធម្មោម្ហិ មរណំ អនតីតោឱ!មនុស្សសត្វនៅលើដុំពិភពលោកនេះទាំងមូលទាំងអស់គ្នាសុទ្ធតែមានសេចក្តីស្លាប់ជាធម្មតាមិនមាននរណាម្នាក់អាចនឹងកន្លងសេចក្តីស្លាប់នេះទៅបានឡើយ!ទាំងខ្លួនរបស់អាត្មានេះឯងក៏ដូចគ្នា។ ព្រោះថាៈ មរណន្តំ ហិ ជីវិតំ ជីវិតរបស់មនុស្សសត្វនៅលើដុំពិភពលោកនេះទាំងមូលទាំងអស់គ្នាសុទ្ធតែមានសេចក្តីស្លាប់នៅខាងចុងបំផុតគ្រប់ៗគ្នា! អធុវំ ជីវិតំ ធុវំ មរណំ ជីវិតមិនទៀងទេ! រីឯសេចក្តីស្លាប់ទៀងណាស់!។ សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ មនុស្សសត្វទាំងអស់! នៅលើដុំពិភពលោកនេះទាំងមូលគង់តែព្រាត់ប្រាសចាកវត្ថុជាទីស្រឡាញ់ពេញចិត្តគ្រប់ៗគ្នាមិនខាន!ទាំងខ្លួនរបស់អាត្មាអញនេះឯង!ក៏ដូចគ្នា!។ កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ ខ្លួនអាត្មាអញនេះមានកម្មជារបស់ខ្លួន, មានកម្មជាអ្នកឲ្យផលមានកម្មជាកំណើត!, មានកម្មជាផៅពង្ស, មានកម្មជាទីពឹង អាស្រ័យ,

អាត្មាអញធ្វើនូវកម្មណា!ជាកម្មល្អក្តីអាក្រក់ក្តី, អាត្មាអញនឹងត្រូវតែជាអ្នកទទួលនូវផលនៃកម្មនោះៗមិនខានឡើយ។ ទាំងប្រជាពលលោកនៅលើដុំពិភពលោកនេះទាំងមូលក៏ដូចគ្នា,ទាំងសព្វមនុស្សសត្វដែលកំពុងមក,ដែលកំពុងទៅ,ដែលកំពុងច្យុត,ដែលកំពុងកើត,ក៏ដូចគ្នាដែរ កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តិ ថ្ងៃនិងយប់!ចេះតែកន្លងទៅ!ៗ, ជីវិតរបស់អាត្មាអញក៏ចេះតែអស់ទៅសូន្យទៅ,ទៅតាមថ្ងៃនិងយប់នោះដែរ តើអាត្មាអញមានបានធ្វើនូវអំពើអ្វីជាលម្អសម្រាប់កំដរជីវិតទៅអនាគតខ្លះហើយដែរទេ?សុញ្ញាគារេ អភិរមាមិ តើអាត្មាអញមានត្រេកអរសម្ងំឋិតនៅក្នុងទីកន្លែងដ៏ស្ងាត់ដើម្បីអប់រំចិត្តឲ្យស្ងប់រម្ងាប់ដែរឬទេ? ម្នាលភិក្ខុទាំងឡាយ! ប្រសិនបើអ្នកចំរើននូវអភិណ្ហបច្ចវេក្ខណធម៌នេះ! ឲ្យរឿយៗទៅ! ចិត្តរបស់អ្នកនឹងបានស្អាតជាបណ្តើរ!ៗ តទៅហើយ!!។

= សាធរ៉ោ! អស់លោកអ្នកសាធុសប្បុរសទាំងឡាយ! គឺចំណុចទាំងប៉ុន្មាននេះឯង!ជាអត្ថន័យនៃការឆ្លើយតបទៅនឹងសំនួរពីខាងដើមនោះហើយ!ដែលឆ្ងល់ថាៈចុះការញ៉ាំងចិត្តឬសំអាតចិត្តឲ្យស្អាតហ្នុង! តើសំអាតយ៉ាងម៉េចទៅ?បើចិត្តមិនមានរូបផង!ចិត្តមើលមិនឃើញផងនោះឥឡូវនេះសូមមេត្តាសង្កេតពិនិត្យឲ្យបានម៉ត់ចត់ច្បាស់លាស់មែនទែនតាមន័យដែលបានពិពណ៌នាមកនេះ! ទើបលោកអ្នកយល់ដល់ជម្រៅនៃអាថ៌សេចក្តីនេះបាន!។និយាយសារុបឡើងវិញដើម្បីបញ្ចប់ថាៈព្រះធម៌!ជាព្រះឱវាទ! របស់ព្រះពុទ្ធមានច្រើនរាប់ម៉ឺនព្រះធម្មក្ខន្ធឬរាប់ម៉ឺនន័យ! តែបើរួបរួមឲ្យខ្លីហើយខ្លឹមមក, នៅត្រឹមតែ៣ព្រះឱស្ឋ! ឬ៣ម៉ាត់តែប៉ុណ្ណោះគឺៈទី១ថាៈ គួរកុំធ្វើអំពើបាបអាក្រក់គ្រប់យ៉ាងគ្រប់ៗគ្នា!។
ទី២ថាៈគួរខំធ្វើអំពើល្អហៅថាបុណ្យគ្រប់យ៉ាងឲ្យបានច្រើនគ្រប់ៗគ្នា!
ទី៣ថាៈគួរខំសំអាតចិត្តរបស់ខ្លួនឲ្យបានស្អាតបរិសុទ្ធផូរផង់គ្រប់ៗគ្នា!
ទាំង៣នេះ ដែលសំខាន់ជាងគេបំផុតនោះគឺព្រះឱវាទប្រការទី៣ដែលចែងថាៈ“សំអាតចិត្តឲ្យស្អាតផូរផង់” នេះឯង! ដោយព្រះឱវាទទាំង២

ខាងដើម, រួមចូលមកក្នុងព្រះឱវាទប្រការទី៣នេះតែទាំងអស់!,ហើយរួមចូលយ៉ាងម៉េចនោះ សូមយើងនាំគ្នាពិចារណាឲ្យបានសុក្រឹតល្អជាបន្តទៅនេះថាៈ ព្រះឱវាទប្រការទី១ ដែលថែងថា!ៈ“គួរកុំធ្វើអំពើបាបអាក្រក់គ្រប់យ៉ាងគ្រប់ៗគ្នា”នោះ គឺថាមនុស្សយើងទាំងអស់នៅលើដុំពិភពលោកទាំងមូលនេះដែលមិនធ្វើអំពើបាបគ្រប់យ៉ាងទៅបានទាល់តែមនុស្សទាំងអស់គ្នាហ្នឹងមានចិត្តស្អាតជាមុនសិន, បើមិនទាន់ស្អាតដល់ថ្នាក់ផូរផង់,ក៏គង់មានចិត្តស្អាតត្រឹមល្មមៗផងដែរទើបមិនធ្វើបាបកើតព្រោះថាមនុស្សយើងបើចិត្តមិនទាន់ស្អាតទេមិនដឹងជាមិនធ្វើបាបយ៉ាងម៉េចកើតទេ, គឺគង់មានពេលណាមួយនឹងភ្លាត់ធ្វើបាបមិនខានពីព្រោះចិត្តវាមិនទាន់ស្អាត!។ ដូច្នេះបានជាថាមនុស្សយើងទាំងអស់គ្នាទាល់តែមានចិត្តស្អាតជាមុនសិន,ទើបមិនធ្វើបាបនោះ,នែ!ហ្នឹងហើយដែលថាៈ រួមចូលក្នុងព្រះឱវាទប្រការទី៣នោះ! គឺរួមចូលក្នុងចិត្តស្អាតហ្នឹងឯង!។ ព្រះឱវាទប្រការទី២- ថែងថា“គួរខំធ្វើអំពើល្អគ្រប់យ៉ាងឲ្យបានច្រើនគ្រប់ៗគ្នា”នោះ, ក៏ត្រូវតែមានចិត្តស្អាតជាមុនផងដែរ, ព្រោះថាមនុស្សយើងនៅលើដុំពិភពលោកនេះទាំងមូលទាំងអស់គ្នាលុះត្រាតែធ្វើចិត្តឲ្យស្អាតជាមុនសិនទើបអាចបំពេញកុសលគ្រប់យ៉ាងទៅកើតឬថាទើបធ្វើអំពើល្អគ្រប់យ៉ាងទៅកើតព្រោះថាៈមនុស្សយើងប្រសិនបើចិត្តមិនទាន់ស្អាតទេមិនដឹងជាធ្វើកុសលយ៉ាងម៉េចកើតទេ, ដូច្នេះបានជាថាៈព្រះឱវាទទាំង២ម៉ាត់ខាងដើមហ្នុង, រួមចូលមកក្នុងព្រះឱវាទប្រការទី៣ដែលថាៈធ្វើចិត្តឲ្យស្អាតផូរផង់នេះឯងតែទាំងអស់!។ សូមឱ្យលោកអ្នកសប្បុរសរំពឹងគិតពិចារណាដោយខ្លួនឯងផ្ទាល់ទៅទៀតផងចុះ!។ = សាធុសប្បុរសទាំងឡាយ!ព្រះឱវាទប្រការទី៣ដែលថែងថាៈគួរខំសំអាតចិត្តរបស់ខ្លួនឲ្យបានស្អាតផូរផង់នេះល្អណាស់! ល្អបំផុត! បានជាថាប្រសើរខ្ពង់ខ្ពស់បំផុតនោះ,ព្រោះថាបើប្រជាពលលោកនៅលើដុំពិភពលោកទាំងមូលនេះ ទោះបីជាតិ-សាសន៍ណាឬទ្វីបណាក៏

ដោយ! ដែលនឹងបានឡើងទៅដល់ស្ថានសួគ៌នោះក៏ដោយសារ“ចិត្ត” ដែលនឹងបានទៅដល់ព្រះនិព្វានជាបរមសុខនោះក៏ដោយសារចិត្ត, គឺ ចិត្តដែលស្អាតបរិសុទ្ធផូរផង់នេះឯង។ប៉ុន្តែក៏កុំភ្លេចថាៈសត្វដែលធ្លាក់ ចុះទៅរងទុក្ខវេទនាក្នុងនរកប៉ុន្មានជាន់នោះ ក៏ដោយសារចិត្តនេះដែរ! ,ប៉ុន្តែជាចិត្តអាក្រក់ចិត្តបាប។មនុស្ស!កាលណាបើមានចិត្តបាបហើយ ប្រាកដជាធ្លាក់ទៅនរកហើយ,ពីព្រោះមានព្រះពុទ្ធដីកាបញ្ជាក់ច្បាស់ ថាៈ ចិត្តេ បរិសុទ្ធេ សុគតិ បាដិកង្ខា អ្នកដែលមានចិត្តស្អាតប្រាកដជា ឡើងទៅឋានសួគ៌ហើយ។ ចិត្តេ សង្កិលិដ្ឋេ ទុគ្គតិ បាដិកង្ខា អ្នកដែល មានចិត្តអាក្រក់មានចិត្តបាប,ប្រាកដជាធ្លាក់ទៅនរកហើយពីព្រោះព្រះ ពុទ្ធដីកាដែលព្រះអង្គ“ពោលហើយ មិនមានពីរ”ឡើយ!។ = សាធុវៅ ហៃសាធុសប្បុរសទាំងឡាយ!ការពិពណ៌នាស្តីអំពីព្រះធម៌រាប់ម៉ឺនព្រះ ធម្មក្ខ័ន្ធឬថារាប់ម៉ឺនន័យរបស់ព្រះពុទ្ធ ដែលរួមឲ្យខ្លីហើយខ្លឹមមក នៅ ត្រឹមតែ៣ព្រះឱស្ឋ, ឬ៣ម៉ាត់ហៅថា“ព្រះឱវាទបាតិមោក្ខ”នោះ!, ទី១-សព្វបាបស្ស អករណំ ការមិនធ្វើបាបអាក្រក់គ្រប់យ៉ាង!,ទី២-កុសលស្សូបសម្បទា គួរខំធ្វើអំពើល្អ បុណ្យ គ្រប់យ៉ាងឲ្យបានច្រើន!។ ទី៣-សចិត្តបរិយោទបនំ គួរខំសំអាតចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់គ្រប់ៗគ្នា! ការសំដែងព្រះធម៌មកនេះ បើចំណុចណាល្អ,មានប្រយោជន៍គួរយក ជាគតិបាន!ក៏ខំព្យាយាមគោរពប្រតិបត្តិតាមទៅ,តែបើត្រង់ចំណុចណា ដែលយល់ថាមិនមានខ្លឹមសារទេ រំលងចោលទៅក៏មិនថ្វី,ព្រោះដូចជា ព្រះរាជឱង្ការសម្តេចព្រះសង្ឃរាជ ជួន-ណាត មួយឃ្លាថាៈធម្មតាការ ងារអ្វីទាំងអស់នៅលើលោកនេះ,តែងមានការភ្លាំងភ្លាត់ខ្លះបើមិនច្រើន ក៏តិចតួចមិនខាន,នេះជាទម្លាប់នៃការងាររបស់បុថុជ្ជន!ព្រោះត្រូវ ជាគូគ្នានិងខុស ,ប៉ុន្តែបើមាន ត្រូវ ច្រើនមាន ខុស តែបន្តិចបន្តួចក៏គង់អាច ប្រើការកើត,គ្រាន់បើជាងគ្មានសោះទៅដែរ!។ **ព្រះធម៌ស្តីពីព្រះឱវាទបី ចប់ដោយសង្ខេបប៉ុណ្ណេះ។**